# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

៣៥៣

# លក្ខន្តិកៈ
# សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត
# នៃព្រះរាជាណាចក្រកម្ពុជា (ស.ជ.ក.រ.ខ)

# *STATUTE*

## *National Association of Capital and Provincial Councils*
## *of the Kingdom of Cambodia (NACPC)*

*លក្ខន្តិកៈ*

*សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា*

## បុព្វកថា

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ


មាត្រា ១ *ឈ្មោះ*

មាត្រា ២ *វិសាលភាព និងការចូលជាធរមាន*


## ជំពូក ២

## អាសយដ្ឋាន រូបសញ្ញា និងត្រា


មាត្រា ៣ *អាសយដ្ឋាន*

មាត្រា ៤ *រូបសញ្ញា និងត្រា*


## ជំពូក ៣

## គោលបំណង និងទិសដៅ


មាត្រា ៥ *គោលបំណង*

មាត្រា ៦ *ទិសដៅ*


## ជំពូក ៤

## រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច


មាត្រា ៧ *រចនាសម្ព័ន្ធ*

មាត្រា ៨-៩ *មហាសន្និបាត*

មាត្រា ១០-១៤ *ក្រុមប្រឹក្សាជាតិ*

មាត្រា ១៥-២០ *គណៈកម្មាធិការប្រតិបត្តិជាតិ*

មាត្រា ២១-២២ *អគ្គលេខាធិការដ្ឋាន*

## ជំពូក ៥
## សមាជិកភាព


មាត្រា ២៣ សមាជិកភាព

មាត្រា ២៤ ល័ក្ខខ័ណ្ឌនៃការចូលជាសមាជិក

មាត្រា ២៥ ការបាត់បង់សមាជិកភាព

មាត្រា ២៦ ការចូលសមាជិកភាពសាជាថ្មី


## ជំពូក ៦
## ធនធាន និងការគ្រប់គ្រង


មាត្រា ២៧ ប្រភពធនធាន

មាត្រា ២៨ ការកំណត់បរិវិសទាន និងភាគទានប្រចាំឆ្នាំ

មាត្រា ២៩ សវនកម្ម និងរបាយការណ៍សវនកម្ម

មាត្រា ៣០ ប្រាក់ឧបត្ថម្ភ

មាត្រា ៣១ ការកែសម្រួល ឬវិសោធនកម្មលក្ខន្តិកៈ

មាត្រា ៣២ ការរំសាយ និងការចាត់ចែងទ្រព្យសម្បត្តិ


## ជំពូក ៧
## អន្តរប្បញ្ញត្តិ


មាត្រា ៣៣ ដំណាក់កាលអន្តរកាល


## ជំពូក ៨
## អវសានប្បញ្ញត្តិ


មាត្រា ៣៤ សុពលភាពគតិយុត្ត

# សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា

## **មុព្វកថា**

អនុលោមតាមស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងជំពូក៣ មាត្រា៤២ ស្តីពីសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងការបង្កើតសមាគម។

អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលតម្រូវឲ្យបង្កើតឡើងនូវក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបោះឆ្នោតអសកលដោយក្រុមប្រឹក្សាឃុំ សង្កាត់។

ដោយហេតុថា ក្រុមប្រឹក្សារាជធានី ខេត្ត នៅកម្ពុជាមានការឯកភាព និងប្តេជ្ញាចិត្តរួមគ្នាក្នុងការលើកកម្ពស់គុណភាពនៃជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋតាមរយៈអភិបាលកិច្ចបែបវិមជ្ឈការ និងវិសហមជ្ឈការ។

ដោយហេតុថា ក្រុមប្រឹក្សារាជធានី ខេត្ត នៅកម្ពុជា មានការប្តេជ្ញាចិត្តជានាដល់ការ អភិវឌ្ឍសមត្ថភាព ដើម្បីជម្រុញការអភិវឌ្ឍ និងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ដោយហេតុថា ក្រុមប្រឹក្សារាជធានី ខេត្ត នៅកម្ពុជា យល់ឃើញថា មានភាពចាំបាច់ក្នុងការទទួលស្គាល់ និងបង្កើតអង្គការរួមមួយរបស់ខ្លួន ដើម្បីជម្រុញ និងកៀរគរក្រុមប្រឹក្សាឱ្យសម្រេចបាននូវការប្តេជ្ញាចិត្តរួមទាំងនេះ។

ដូច្នេះ ក្រុមប្រឹក្សារាជធានី ខេត្ត នៅកម្ពុជា សម្រេចចិត្តរួមគ្នាបង្កើតសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ដែលតំណាងឲ្យក្រុមប្រឹក្សារាជធានី ខេត្ត ទូទាំងប្រទេស។

## **ជំពូក ១**

## **បទប្បញ្ញត្តិទូទៅ**

**មាត្រា ១.- *ឈ្មោះ***

សមាគមនេះមានឈ្មោះថា "សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត" នៃព្រះរាជាណាចក្រកម្ពុជា សរសេរជាអក្សរកាត់ "ស.ជ.ក.រ.ខ" និងមានឈ្មោះជាភាសាអង់គ្លេសថា *National Association of Capital and Provincial Councils of the Kingdom of Cambodia (NACPC)* ដោយមានឈ្មោះហៅកាត់ថា " សមាគមជាតិក្រុមប្រឹក្សាថ្នាក់តំបន់ " និងជាភាសាអង់គ្លេស "*National Association of Regional Councils*"។

### មាត្រា ២.- វិសាលភាព និងការចូលជាធរមាន

លក្ខន្តិកៈនេះ មានវិសាលភាពអនុវត្តក្នុងក្រុមខណ្ឌសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។

លក្ខន្តិកៈនេះ ចូលជាធរមានបន្ទាប់ពីសេចក្តីសម្រេចរបស់មហាសន្និបាត។ សេចក្តីសម្រេចនេះ ត្រូវអនុម័តដោយការបោះឆ្នោតដែលមានសម្លេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាល (ហាសិបភាគរយបូកមួយ) នៃចំនួនប្រតិភូពេញសិទ្ធិចូលរួមនៅក្នុងមហាសន្និបាត។

## ជំពូក ២

## អាសយដ្ឋាន រូបសញ្ញា និងត្រា

### មាត្រា ៣. អាសយដ្ឋាន

សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត មានទីស្នាក់ការកណ្តាលស្ថិតនៅរាជធានីភ្នំពេញ ឬខេត្ត។ សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត អាចរៀបចំកម្រងរបស់ខ្លួនបានតាមស្ថានភាពជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### មាត្រា ៤.- រូបសញ្ញា និងត្រា

រូបសញ្ញាជាផ្លូវការរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត គឺមានរូបផែនទីព្រះរាជាណាចក្រកម្ពុជា ដោយមានផ្ទៃខាងក្រោយពណ៌ទឹកសមុទ្រ ក្នុងផែនទីមានរូបប្រាសាទអង្គរវត្ត ព័ទ្ធជារង្វង់ដោយកួរស្រូវពណ៌មាសភ្ជាប់ដោយខ្សែបូ អមដោយក្បាច់ភ្ញីល្ងើពណ៌មាស និងចារិកអក្សរថា "ស.ជ.ក.រ.ខ" មានអក្សរជារង្វង់ស្នែងក្របីផ្នែកខាងក្នុងកួរស្រូវសរសេរថា "សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត " និងជាភាសាអង់គ្លេសថា "National Association of Capital and Provincial Councils"។

សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវមានត្រាជាផ្លូវការរបស់ខ្លួន។ ត្រារបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត មានសណ្ឋានជារង្វង់មូលពីរជាន់។ រង្វង់ខាងក្រៅមានវិជ្ជមាត្រ ៣.៤សង់ទីម៉ែត្រ និងរង្វង់ខាងក្នុងមានវិជ្ជមាត្រ ២.៨សង់ទីម៉ែត្រ។ ផ្នែកខាងលើនៃរង្វង់ត្រា មានចារិកអក្សរខ្មែរថា "ព្រះរាជាណាចក្រកម្ពុជា" និងនៅផ្នែកខាងក្រោមមានចារិកអក្សរខ្មែរថា "សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត" ហើយខណ្ឌដោយផ្កាចាន់។ នៅចំណុចកណ្តាលនៃត្រាមានរូបផែនទីប្រទេសកម្ពុជា និងមានចារិកអក្សរថា "ស.ជ.ក.រ.ខ" និងជាភាសាអង់គ្លេសថា "NACPC"។

# ជំពូក ៣
## គោលបំណង និងទិសដៅ

**មាត្រា ៥.- *គោលបំណង***

*គោលបំណងរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត គឺ៖*

- *លើកកម្ពស់ឋានៈ និងអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សារាជធានី ខេត្ត*
- *ការពារផលប្រយោជន៍ និងគុណប្រយោជន៍ស្របច្បាប់របស់សមាជិក*
- *កសាងភាពជាដៃគូជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអភិវឌ្ឍន៍មូលដ្ឋាន ពង្រឹងនីតិរដ្ឋ និងជម្រុញលលិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។*

**មាត្រា ៦.- *ទិសដៅ***

*ទិសដៅរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត គឺ៖*

- *ពង្រឹងស្ថាប័នសមាគមជាតិក្រុមប្រឹក្សារាជធានីខេត្តដែលជា យន្តការតំណាងឲ្យក្រុមប្រឹក្សារាជធានី ខេត្ត ទូទាំងប្រទេសឱ្យមានសមត្ថភាព ជំនាញ និងវិជ្ជាជីវៈ ដើម្បីធ្វើសកម្មភាពបម្រើផលប្រយោជន៍សមាជិក*
- *ពង្រឹងចីរភាពហិរញ្ញវត្ថុរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត តាមរយៈយន្តការ និងនីតិវិធី ដែលធានាដល់ចីរភាពហិរញ្ញវត្ថុ ដែលមិនប៉ះពាល់ឯករាជ្យភាពរបស់សមាគម*
- *អភិវឌ្ឍសមត្ថភាពសមាជិកក្រុមប្រឹក្សារាជធានីខេត្តតាមរយៈការបណ្តុះបណ្តាល និងការចែករំលែកបទពិសោធន៍ពីគ្នាទៅវិញទៅមក*
- *ទំនាក់ទំនង និងសម្របសម្រួលលើរាល់បញ្ហា និងតម្រូវការរួមរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ*
- *លើកកម្ពស់សមធម៌យេនឌ័រនៅក្នុងគោលនយោបាយមូលដ្ឋានតាមរយៈការធានាឲ្យមានការចូលរួម និងភាពជាតំណាងរបស់ស្ត្រីនៅក្នុងសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត និងក្នុងក្រុមប្រឹក្សារាជធានី ខេត្ត*
- *ជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងគិតគូពីការប្រែប្រួលអាកាសធាតុដោយមានការចូលរួមនៅក្នុងសកម្មភាពរបស់ក្រុមប្រឹក្សារាជធានីខេត្ត ដែលជាសមាជិក។*

# ជំពូក៤
# រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច

## មាត្រា ៧.- *រចនាសម្ព័ន្ធ*

*សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត មានរចនាសម្ព័ន្ធដូចខាងក្រោម៖*

- *មហាសន្និបាត*
- *ក្រុមប្រឹក្សាជាតិ*
- *គណៈកម្មាធិការប្រតិបត្តិជាតិ*
- *អគ្គលេខាធិការដ្ឋាន។*

## មាត្រា ៨.- **មហាសន្និបាត**

*មហាសន្និបាត ត្រូវរៀបចំឡើងរៀងរាល់ប្រាំឆ្នាំម្តង នៅប្រទេសកម្ពុជា។ មហាសន្និបាត ត្រូវប្រារព្ធឡើងតាមការសម្រេចរបស់ក្រុមប្រឹក្សាជាតិនៃសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។*

*មហាសន្និបាតត្រូវមានប្រតិភូ ចូលរួមមកពីក្រុមប្រឹក្សារាជធានី ខេត្ត។*

*ក្រៅពីមហាសន្និបាតក្នុងរយៈពេលប្រាំឆ្នាំម្តង សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត អាចរៀបចំមហាសន្និបាតវិសាមញ្ញ នៅពេលណាមួយនៅប្រទេសកម្ពុជា ដើម្បីពិចារណាការងារដែលជាផលប្រយោជន៍របស់សមាគម ដើម្បីពិនិត្យ និងដោះស្រាយបញ្ហានៅមុនមហាសន្និបាត នាពេលបន្ទាប់។*

*ប្រធាន និងអនុប្រធានសមាគម មានភារកិច្ចចាត់ចែង រៀបចំមហាសន្និបាតនៅរៀងរាល់ប្រាំឆ្នាំម្តង។*

*ប្រធាន និងអនុប្រធានសមាគម ត្រូវពិនិត្យលទ្ធភាព និងចាត់ចែងរៀបចំមហាសន្និបាតវិសាមញ្ញនៅពេលមានសំណើជាលាយល័ក្ខណ៍អក្សរ ដោយមានបញ្ជាក់ប្រធានបទ និងមូលហេតុពីសំណាក់ ៖*

- *ក្រុមប្រឹក្សារាជធានី ខេត្តដែលជាសមាជិករបស់សមាគមយ៉ាងតិច ពីរភាគបី ឬ*
- *សមាជិកក្រុមប្រឹក្សាជាតិ យ៉ាងតិច ពីរភាគបី ឬ*
- *សមាជិកគណៈកម្មាធិការប្រតិបត្តិជាតិ ទាំងមូល។*

*សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ដែលត្រូវបានបញ្ចប់អាណត្តិ ត្រូវរៀបចំ*

មហាសន្និបាតរយៈពេល ៦ខែ ក្រោយពីការបោះឆ្នោតអាណត្តិថ្មីរបស់ក្រុមប្រឹក្សារាជធានី ខេត្ត។

**មាត្រា ០៩.-តួនាទី និងភារកិច្ចមហាសន្និបាត**

មហាសន្និបាតមានតួនាទី និងភារកិច្ចៈ

- បោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានសមាគម
- បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាជាតិរបស់សមាគម
- អនុម័តលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងគោលនយោបាយរបស់សមាគម
- អនុម័តរូបសញ្ញា និងត្រាជាផ្លូវការរបស់សមាគម
- កំណត់ល័ក្ខខ័ណ្ឌសម្រាប់ការចូលនិងការបាត់បង់ជាសមាជិកភាពរបស់សមាគម
- វាយតម្លៃលើសមិទ្ធផលដែលសម្រេចបាន ដោយអនុលោមតាមគោលបំណង និងទិសដៅរបស់សមាគម
- ពិនិត្យមើលឡើងវិញ និងសម្រេចលើកិច្ចការដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាជាតិ
- កែសម្រួល និងវិសោធនកម្មលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង របស់សមាគម
- ប្រតិភូកម្មសិទ្ធិអំណាចក្នុងការសម្រេចការងារចាំបាច់ដទៃទៀតដល់ក្រុមប្រឹក្សាជាតិរបស់សមាគម
- សម្រេចលើការរំសាយ និងចាត់ចែងទ្រព្យសម្បត្តិរបស់សមាគម។

**មាត្រា ១០.- ក្រុមប្រឹក្សាជាតិ**

ប្រធាន អនុប្រធានសមាគម គឺជាប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សាជាតិ។ ក្រុមប្រឹក្សាជាតិមានសមាសភាពៈ

- ប្រធានអនុប្រធាននិងសមាជិកក្រុមប្រឹក្សាជាតិតំណាងឲ្យក្រុមប្រឹក្សារាជធានី ខេត្ត ទូទាំងប្រទេស មកពីគ្រប់គណបក្សនយោបាយដែលមានអាសនៈក្នុងក្រុមប្រឹក្សា និងសមាជិកក្រុមប្រឹក្សាជាស្ត្រី។
- ប្រធាន អនុប្រធាន និងសមាជិកក្រុមប្រឹក្សាជាតិ មានចំនួនយ៉ាងតិចជាង ១៥ភាគរយ នៃចំនួនអាសនៈក្រុមប្រឹក្សារាជធានី ខេត្ត ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រតិភូមហាសន្និបាត ពីក្នុងចំណោមប្រតិភូចូលរួមនៅក្នុងមហាសន្និបាត។

**មាត្រា ១១.- អាណត្តិក្រុមប្រឹក្សាជាតិ**

ក្រុមប្រឹក្សាជាតិ មានអាណត្តិ ៥ឆ្នាំ។ ប្រធាន ឬអនុប្រធាន ឬសមាជិកក្រុមប្រឹក្សាជាតិ អាចត្រូវបានបញ្ឈប់មុនអាណត្តិដោយសេចក្ដីសម្រេចរបស់កិច្ចប្រជុំក្រុមប្រឹក្សាជាតិ។

ប្រធាន ឬអនុប្រធាន ឬសមាជិកក្រុមប្រឹក្សាជាតិណាដែលបាត់បង់សមាជិកភាពជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបាត់បង់សមាជិកភាពពីសមាជិកក្រុមប្រឹក្សាជាតិដោយស្វ័យប្រវត្តិ។

**មាត្រា ១២.- កិច្ចប្រជុំក្រុមប្រឹក្សាជាតិ**

ក្រុមប្រឹក្សាជាតិ ត្រូវធ្វើការប្រជុំសាមញ្ញមួយឆ្នាំម្ដង នៅក្នុងប្រទេសកម្ពុជា។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាជាតិ អាចរៀបចំកិច្ចប្រជុំវិសាមញ្ញបាន តាមល័ក្ខខ័ណ្ឌដូចខាងក្រោម៖

- តាមការសម្រេចរបស់ប្រធាន និងអនុប្រធានសមាគម ឬ
- តាមការស្នើសុំពីសមាជិកក្រុមប្រឹក្សាជាតិចំនួនពីរភាគបី ឬ
- តាមការស្នើសុំពីសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិទាំងមូល។

សមាជិកក្រុមប្រឹក្សាជាតិគ្រប់រូប មានសិទ្ធិបោះឆ្នោតមួយសម្លេងនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាតិ។ ក្នុងករណីមានសម្លេងឆ្នោតស្មើគ្នា សម្លេងរបស់ប្រធានក្រុមប្រឹក្សាជាតិ មានឧត្តមានុភាព។

**មាត្រា ១៣.- តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិ**

ក្រុមប្រឹក្សាជាតិមានតួនាទី និងភារកិច្ច ៖

- **ពិនិត្យ** និងអនុម័តក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់សមាគម
- គ្រប់គ្រង និងដឹកនាំការងារសមាគម នៅចន្លោះពេលមហាសន្និបាត ដោយអនុលោមតាមគោលបំណងនិងទិសដៅរបស់សមាគមដូចមានចែងក្នុងលក្ខន្តិកៈ
- **ពិនិត្យ** និងធ្វើវិសោធនកម្មលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងក្នុងករណីចាំបាច់
- **ពិនិត្យ** និងអនុម័តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់សមាគម
- ពិនិត្យ និងវាយតម្លៃលើរបាយការណ៍សវនកម្មផ្ទៃក្នុងប្រចាំឆ្នាំរបស់សមាគម
- **រៀបចំ**របាយការណ៍សកម្មភាពនិងផ្ដល់អនុសាសន៍អំពីជាលាយល័ក្ខណ៍អក្សរ និងដាក់របាយការណ៍សវនកម្មផ្ទៃក្នុងជូនមហាសន្និបាត

- អនុម័តសមាសភាពសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិរបស់សមាគម
- ប្រតិភូកម្មសិទ្ធិអំណាចក្នុងការសម្រេចការងារចាំបាច់ដទៃទៀត ដល់គណៈកម្មាធិការប្រតិបត្តិជាតិរបស់សមាគម។

**មាត្រា ១៤.- *ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាជាតិ***

ប្រធានក្រុមប្រឹក្សាជាតិមានភារកិច្ចៈ

- ចាត់ចែង រាល់កិច្ចប្រជុំក្រុមប្រឹក្សាជាតិ
- ជាប្រធានអង្គប្រជុំក្រុមប្រឹក្សាជាតិ
- អនុវត្តភារកិច្ចផ្សេងៗ ដែលតម្រូវដោយលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុង
- ផ្ទេរសិទ្ធិជាប្រធានស្តីទីដល់អនុប្រធានណាមួយក្នុងពេលអវត្តមាន។

**មាត្រា ១៥.- *គណៈកម្មាធិការប្រតិបត្តិជាតិ***

ប្រធាន និងអនុប្រធានក្រុមប្រឹក្សាជាតិ គឺជាប្រធាន អនុប្រធានគណៈកម្មាធិការប្រតិបត្តិជាតិ។

សមាជិកគណៈកម្មាធិការប្រតិបត្តិជាតិ ត្រូវអនុម័តដោយក្រុមប្រឹក្សាជាតិ។

គណៈកម្មាធិការប្រតិបត្តិជាតិ មានសមាសភាព ៖

- សមាជិកក្រុមប្រឹក្សាជាតិតំណាងឲ្យក្រុមប្រឹក្សារាជធានីខេត្តទូទាំងប្រទេស មកពីគ្រប់គណបក្សនយោបាយដែលមានអាសនៈក្នុងក្រុមប្រឹក្សា និងសមាជិកក្រុមប្រឹក្សាជាស្ត្រី
- ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិ មានចំនួនមិនតិចជាង ៥០ភាគរយ នៃចំនួនក្រុមប្រឹក្សាជាតិ។ សមាជិកគណៈកម្មាធិការប្រតិបត្តិជាតិត្រូវ ត្រូវបានបោះឆ្នោតជ្រើសរើសឡើង ដោយក្រុមប្រឹក្សាជាតិពីក្នុងចំណោមសមាជិកក្រុមប្រឹក្សាជាតិ។

**មាត្រា ១៦.- *អាណត្តិរបស់គណៈកម្មាធិការប្រតិបត្តិជាតិ***

គណៈកម្មាធិការប្រតិបត្តិជាតិ មានអាណត្តិ ៥ឆ្នាំ។ ប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិ អាចត្រូវបានបញ្ឈប់មុនអាណត្តិដោយសេចក្តីសម្រេចរបស់កិច្ចប្រជុំក្រុមប្រឹក្សាជាតិ។

ប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិណាដែលបាត់បង់សមាជិកភាព ជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបាត់បង់សមាជិកភាពពីសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិដោយស្វ័យប្រវត្តិ។

**មាត្រា ១៧.- កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិ**

គណៈកម្មាធិការប្រតិបត្តិជាតិ ត្រូវធ្វើការប្រជុំសាមញ្ញយ៉ាងតិចពីរដងមួយឆ្នាំនៅក្នុងប្រទេសកម្ពុជា។

ក្នុងករណីចាំបាច់ គណៈកម្មាធិការប្រតិបត្តិជាតិ អាចរៀបចំកិច្ចប្រជុំវិសាមញ្ញបានតាមល័ក្ខខ័ណ្ឌ ដូចខាងក្រោម៖

- តាមការសម្រេចរបស់ប្រធាន និងអនុប្រធានសមាគម ឬ
- តាមការស្នើសុំពីសមាជិកគណៈកម្មាធិការប្រតិបត្តិជាតិចំនួនពីរភាគបី។

សមាជិកគណៈកម្មាធិការប្រតិបត្តិជាតិគ្រប់រូប មានសិទ្ធិបោះឆ្នោតមួយសម្លេងនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិ។ ក្នុងករណីមានសម្លេងឆ្នោតស្មើគ្នា សម្លេងរបស់ប្រធាន គណៈកម្មាធិការប្រតិបត្តិជាតិ មានឧត្តមានុភាព។

**មាត្រា ១៨.- តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការប្រតិបត្តិជាតិ**

គណៈកម្មាធិការប្រតិបត្តិជាតិ មានតួនាទី និងភារកិច្ច ៖

- រៀបចំ និងចងក្រងក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់សមាគម
- ពិនិត្យ និងអនុម័តផែនការសកម្មភាព និងថវិកាប្រចាំឆមាស
- តាមដាន និងវាយតម្លៃការអនុវត្តការងារ វឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយ របស់សមាគមប្រចាំឆមាស
- ផ្តួចផ្តើម និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាជាតិ
- ត្រួតពិនិត្យកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុរបស់សមាគម
- ពិនិត្យ និងអនុម័តគោលនយោបាយគ្រប់គ្រងបុគ្គលិក ឬទីប្រឹក្សា
- រៀបចំរបាយការណ៍សកម្មភាពនិងផ្តល់អនុសាសន៍ជាលាយល័ក្ខណ៍អក្សរ និងដាក់របាយការណ៍សវនកម្មផ្ទៃក្នុងជូនក្រុមប្រឹក្សាជាតិ
- ប្រតិភូកម្មសិទ្ធិអំណាចក្នុងការសម្រេចការងារចាំបាច់ដទៃទៀត ដល់ប្រធាន និងអនុប្រធានសមាគម

**មាត្រា ១៩.- *ភារកិច្ចរបស់ប្រធានគណៈកម្មាធិការប្រតិបត្តិជាតិ***

ប្រធានគណៈកម្មាធិការប្រតិបត្តិជាតិ មានភារកិច្ច ៖

- ចាត់ចែង រាល់កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិ
- ជាប្រធានអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិ
- អនុវត្តភារកិច្ចផ្សេងៗ ដែលតម្រូវដោយលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុង
- ផ្ទេរសិទ្ធិជាប្រធានស្តីទីដល់អនុប្រធានណាមួយក្នុងពេលអវត្តមាន
- មានសិទ្ធិតែងតាំង និងបញ្ឈប់ទីប្រឹក្សាសមាគម។

**មាត្រា ២០.- *គណៈកម្មការជំនាញ***

គណៈកម្មាធិការប្រតិបត្តិជាតិ អាចបង្កើត ឬរំសាយគណៈកម្មការជំនាញរបស់សមាគម។

គណៈកម្មាធិការប្រតិបត្តិជាតិ ត្រូវសម្រេចលើល័ក្ខខ័ណ្ឌការងារ និងសិទ្ធិអំណាចរបស់គណៈកម្មការជំនាញនីមួយៗ។

**មាត្រា ២១.- *អគ្គលេខាធិការដ្ឋាន***

សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត មានអគ្គលេខាធិការដ្ឋានរបស់ខ្លួនដើម្បីគ្រប់គ្រងការងារប្រចាំថ្ងៃរបស់សមាគម និងផ្នែកនានារបស់សមាគម និងរៀបចំចាត់ចែងមហាសន្និបាត កិច្ចប្រជុំក្រុមប្រឹក្សាជាតិ និងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិ។

អគ្គលេខាធិការដ្ឋានសមាគម ត្រូវដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយចំនួនជាជំនួយការ។

អគ្គលេខាធិការ ត្រូវចូលរួម និងអាចមានមតិនៅក្នុងអង្គប្រជុំទាំងអស់ ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោត និងអនុម័តឡើយ។

**មាត្រា ២២.- *លក្ខណៈសម្បត្តិ និងតួនាទី និងភារកិច្ចរបស់អគ្គលេខាធិការ***

អគ្គលេខាធិការ ត្រូវមានលក្ខណៈសម្បត្តិ និងបទពិសោធន៍វិជ្ជាជីវៈសមស្របលើការងារអភិបាលកិច្ច និងការអភិវឌ្ឍមូលដ្ឋាន។ អគ្គលេខាធិការ ត្រូវបំពេញការងារពេញម៉ោង។

អគ្គលេខាធិការមានភារកិច្ច៖

- គ្រប់គ្រងការងារប្រចាំថ្ងៃរបស់សមាគម

- គ្រប់គ្រងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុរបស់សមាគម
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់សមាគម
- គ្រប់គ្រងបុគ្គលិកទាំងអស់នៃអង្គភាពចំណុះអគ្គលេខាធិការដ្ឋានរបស់សមាគម
- ផ្តល់យោបល់ និងរៀបចំរបាយការណ៍ជូនមហាសន្និបាត ប្រធាន និងអនុប្រធានសមាគម ក្រុមប្រឹក្សាជាតិ គណៈកម្មាធិការប្រតិបត្តិជាតិ និងគណៈកម្មការនានា
- ទទួលខុសត្រូវលើកិច្ចការផ្សេងទៀត តាមល័ក្ខខ័ណ្ឌការងារចាំបាច់។

## ជំពូក ៥
## សមាជិកភាព

**មាត្រា ២៣.- សមាជិកភាព**

សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត រួមមានក្រុមប្រឹក្សារាជធានី ខេត្ត ក្នុងប្រទេសកម្ពុជា ជាសមាជិក។

សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត នឹងចាប់បដិសន្ធិនៅពេលដែលក្រុមប្រឹក្សារាជធានី ខេត្ត យ៉ាងតិចចំនួនមួយភាគបីស្ម័គ្រចិត្តសុំចូល ជាសមាជិក។

**មាត្រា ២៤.- ល័ក្ខខ័ណ្ឌនៃការចូលជាសមាជិក**

ដើម្បីចូលជាសមាជិករបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម៖

- ដាក់ពាក្យសុំចូលដោយស្ម័គ្រចិត្ត និងដោយមានសម្លេងយល់ព្រមយ៉ាងតិចហាសិបភាគរយបូកមួយ នៃចំនួនសមាជិកក្រុមប្រឹក្សារាជធានី ខេត្តសាមី
- យល់ព្រមអនុវត្តតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត
- យល់ព្រមបង់ប្រាក់ភាគទានប្រចាំឆ្នាំ ។

**មាត្រា ២៥.- ការបាត់បង់សមាជិកភាព**

សមាជិកភាពរបស់សមាគម នឹងត្រូវបាត់បង់តាមករណីណាមួយដូចខាងក្រោម៖

- ដាក់ពាក្យសុំលាលែងដោយស្ម័គ្រចិត្តនិងដោយមានសម្លេងយល់ព្រមយ៉ាងតិចពីរភាគបីនៃចំនួនសមាជិកទាំងអស់របស់ក្រុមប្រឹក្សារាជធានី ខេត្តសាមី

- មិនបានបង់ប្រាក់ភាគទានប្រចាំឆ្នាំតាមកាលកំណត់ចំនួនពីរឆ្នាំជាប់គ្នាដោយគ្មានមូលហេតុ
- រំលោភលក្ខន្តិកៈរបស់សមាគម។

មាត្រា ២៦.- **ការចូលសមាជិកភាពសារជាថ្មី**

ការចូលជាសមាជិកភាពសារជាថ្មីរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបំពេញតាមល័ក្ខខ័ណ្ឌដូចខាងក្រោម៖

- ស្ម័គ្រចិត្តដាក់ពាក្យសុំចូលសមាជិកជាថ្មីម្តងទៀត
- ស្ម័គ្រចិត្តបង់ប្រាក់ភាគទានប្រចាំឆ្នាំដែលខ្លួនមិនបានបង់ឲ្យគ្រប់ចំនួនឡើងវិញ។

## ជំពូក ៦
## ធនធាន និងការគ្រប់គ្រង

មាត្រា ២៧.- **ប្រភពធនធានរបស់សមាគម**

ធនធានរបស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត បានមកពី៖

- បរិវិសទាន និងភាគទានរបស់សមាជិក
- អំណោយ និងមរតកសាសន៍
- អតិរេក ឬប្រាក់សន្សំពីកម្មវិធី ឬចំណូលបានមកពីសកម្មភាពស្របច្បាប់របស់សមាគម
- វិភាជន៍ពីរាជរដ្ឋាភិបាល និងទីភ្នាក់ងារផ្តល់ជំនួយនានា
- ប្រភពស្របច្បាប់ផ្សេងទៀតដែលមិនធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់សមាគម។

មាត្រា ២៨.- **ការកំណត់បរិវិសទាន និងភាគទានប្រចាំឆ្នាំ**

គណៈកម្មាធិការប្រតិបត្តិជាតិ ត្រូវពិនិត្យ និងកំណត់ចំនួនទឹកប្រាក់បរិវិសទាន និងភាគទានប្រចាំឆ្នាំដែលសមាជិកសមាគម ត្រូវបង់ ដើម្បីឱ្យមានសមធម៌ និងអាចធានាបានដល់ប្រតិបត្តិការរបស់សមាគម។

មាត្រា ២៩.- **សវនកម្ម និងរបាយការណ៍សវនកម្ម**

រៀងរាល់ឆ្នាំគណៈកម្មាធិការប្រតិបត្តិជាតិ ត្រូវតែងតាំងសវនករដើម្បីធ្វើសវនកម្មលើកិច្ចការទូទៅរបស់សមាគម។

សវនករ ត្រូវតែជាសវនករដែលបានចុះបញ្ជីដោយឯករាជ្យ នឹងមានការទទួលស្គាល់ជាលក្ខណៈជាតិ និងអន្តរជាតិ ក្នុងការធ្វើសវនកម្ម។

បន្ទាប់ពីបានបញ្ចប់ការធ្វើសវនកម្ម សវនករត្រូវដាក់របាយការណ៍សវនកម្មជូនប្រធាន អនុប្រធានសមាគម គណៈកម្មាធិការប្រតិបត្តិជាតិ ដើម្បីធ្វើការ ពិនិត្យ ពិភាក្សា និងអនុម័ត។ ច្បាប់ចម្លងនៃរបាយការណ៍សវនកម្មត្រូវផ្តល់ជូនជាបន្ទាន់ដល់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រសួង ស្ថាប័នពាក់ព័ន្ធ និងទីភ្នាក់ងារទាំងអស់ដែលបានផ្តល់ការគាំទ្រដល់សមាគម ។

### មាត្រា ៣០.- ប្រាក់ឧបត្ថម្ភ

ប្រធាន អនុប្រធានសមាគម អាចទទួល ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ ដែលសម្រេចដោយគណៈកម្មាធិការប្រតិបត្តិជាតិ។

### មាត្រា ៣១.- ការកែសម្រួល ឬវិសោធនកម្មលក្ខន្តិកៈ

លក្ខន្តិកៈនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មដោយសេចក្តីសម្រេចរបស់មហាសន្និបាត។

លក្ខន្តិកៈនេះអាចធ្វើវិសោធនកម្មដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជាតិ។

### មាត្រា ៣២.- ការចាត់ចែងទ្រព្យសម្បត្តិនៅពេលរំសាយ

មហាសន្និបាត គឺជាស្ថាប័នខ្ពស់បំផុត ដែលមានសិទ្ធិរំសាយសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត។ ក្នុងករណីសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវបានប្រកាសរំសាយ ទ្រព្យសម្បត្តិទាំងអស់របស់សមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវផ្ទេរឱ្យមូលនិធិក្រុមប្រឹក្សារាជធានី ខេត្ត។

## ជំពូក ៧

## អន្តរប្បញ្ញត្តិ

### មាត្រា ៣៣.- ដំណាក់កាលអន្តរកាល

សមាជិកចូលរួមក្នុងមហាសន្និបាតសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្តលើកទី១ ត្រូវកំណត់ដោយក្រុមការងារថ្នាក់ជាតិ។

ប្រធាន និងអនុប្រធានក្រុមការងារថ្នាក់ជាតិ គឺជាប្រធាន និងអនុប្រធានដឹកនាំមហាសន្និបាតលើកទី១។

អគ្គលេខាធិការដ្ឋានសម្ព័ន្ធភាពជាតិឃុំ សង្កាត់ ក្នុងនាមអនុកម្មវិធីទី៦ នៃ ផ.អ.៣ មានភារកិច្ចចាត់ចែង រៀបចំមហាសន្និបាត បង្កើតសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ។

## ជំពូក ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៣៩.- *សុពលភាពគតិយុត្ត***

លក្ខន្តិកៈសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្តមានសុពលភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០១៣

**ប្រធាន**